ធ៩-៩៨-៤១១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ តាមរយៈធនាគារជាតិនៃកម្ពុជា

**ប្រការ ១**.-

បញ្ឈប់ការផ្តល់ទិដ្ឋាការឱ្យធនាគារពាណិជ្ជនាំចេញនូវសាច់ប្រាក់ជាដុល្លារអាមេរិកតទៅទៀត ដោយអនុញ្ញាតឱ្យធ្វើការផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ធនាគារពាណិជ្ជដែលមានបំណងផ្ទេរសាច់ប្រាក់ដុល្លារចេញ ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់)។

**ប្រការ ៣**.-

សោហ៊ុយសេវាក្នុងប្រតិបត្តិការផ្ទេរប្រាក់ នឹងត្រូវកំណត់ទៅតាមកាលៈទេសៈតម្រូវការសាច់ប្រាក់ដុល្លារ អាស្រ័យដោយអគ្គនាយកដ្ឋានធនាគារជាតិនៃកម្ពុជា ជាអ្នកសំរេចចេញសេចក្តីជូនដំណឹងឱ្យអនុវត្តជាក់ស្តែងប្រចាំគ្រានីមួយៗ។

**ប្រការ ៤**.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ជាពិសេសប្រកាសលេខ ធ៧-៩៨-៣៦៦ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ និងប្រកាស លេខធ៩-៩៨-៣៨៦ ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាមានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**